**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥០.៥ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការកែសម្រួលសមាសភាពក្រុមការងារចម្រុះ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គភាពប្រឆាំងអំពើពុករលួយ និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សម្រាប់ពិនិត្យប្រាក់សម្រួលការងារ(កម្រៃសេវា)

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.ប្រក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើង ទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋាន គយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋាន រតនាគារជាតិ ស្ថិតនៅក្រោមការគ្រប់គ្រង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២៣០ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩០ សហវ.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១**: ត្រូវបានកែសម្រួលសមាសភាពក្រុមការងារចម្រុះ សម្រាប់ពិនិត្យប្រាក់សម្រួលការងារ(កម្រៃសេវា) ដែលបានបង្កើតឡើងតាមរយៈប្រកាសលេខ ២៣០ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ និងប្រកាសលេខ ១៩០ សហវ.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ជូ គឹមឡេង** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្តម **វង្សី វិស្សុត** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣. | ឯកឧត្តម **ហ៊ាន សាហ៊ីប** | អគ្គលេខាធិការ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ៤. | ឯកឧត្តម **យស់ ស៊ីណាត** | ជំនួយការទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |
| ៥. | ឯកឧត្តម **សម្បត្តិ ហ៊ីណា** | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រតិបត្តិការ នៃអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |
| ៦. | ឯកឧត្តម **វង់ សណ្ដាប់** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. | ឯកឧត្តម **លីវ ម៉ុនហៃ** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨. | ឯកឧត្តម **ហាច រតនៈ** | អគ្គលេខាធិការរង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ៩. | ឯកឧត្តម **ទេព្យ តិឃ្មោរិទ្ធ** | ប្រធានផ្នែកស្រាវជ្រាវគោលនយោបាយសេដ្ឋកិច្ច នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ១០. | លោក **អូន ម៉ុនហាក់** | ប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១. | លោក **សុខ សារាវុឌ្ឍ** | ប្រធាននាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

| | | |
|---|---|---|
| ១២. លោក **នេត មុន្នី** | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣. លោក **គីម ផល្លា** | ប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤. លោក **អៀង ស៊ុនលី** | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥. លោក **ហ៊ើល ចំរើន** | ប្រធាននាយកដ្ឋាននីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៦. លោកស្រី **ម៉ា សូយ៉ិនដា** | ប្រធាននាយកដ្ឋានអប់រំ បង្ការ និងទប់ស្កាត់ នៃអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |
| ១៧. លោក **ម៉ែន ឧត្តា** | អនុប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៨. លោក **ម៉ៅ បុញ្ញខេត្ត** | អនុប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៩. លោក **ទេព វណ្ណារា** | អនុប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២០. លោក **ផាត ពិសី** | អនុប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២១. កញ្ញា **នខ សុនាវី** | អនុប្រធាននាយកដ្ឋានចារកម្ម និងស៊ើបអង្កេត នៃអង្គភាពប្រឆាំងអំពើ ពុករលួយ | សមាជិក |
| ២២. លោក **ញ៉ែម មូរ៉ា** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |
| ២៣. លោកស្រី **អ៊ូ ស៊ីថា** | អនុប្រធាននាយកដ្ឋានអប់រំ បង្ការ និងទប់ស្កាត់ នៃអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |
| ២៤. លោកស្រី **កែម សុភាព** | អនុប្រធានការិយាល័យលទ្ធកម្ម នៃអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |

**ប្រការ ២:** ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចតទៅ ៖

- ពិនិត្យប្រាក់សម្រួលការងារ(កម្រៃសេវា) របស់ក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ តាមលំដាប់អាទិភាព ជាបន្តបន្ទាប់។
- អញ្ជើញក្រសួង ស្ថាប័ន និងមន្ត្រីពាក់ព័ន្ធ ដើម្បីពិនិត្យកម្រៃសេវា និងរៀបចំសេចក្តីព្រាងប្រកាសសម្រាប់អនុវត្តកម្រៃសេវានេះ។
- ធ្វើការបូកសរុបលទ្ធផលការងារជាដំហានៗ ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីមានវិធានការ និងផ្តល់ការណែនាំ ជាយថាហេតុ។
- ពិនិត្យ និងកែសម្រួលឱ្យបានសមស្របតាមស្ថានភាពជាក់ស្តែង ទៅតាមដំណាក់កាលនីមួយៗ នូវប្រកាសដែលបានចូលជាធរមានហើយ។

**ប្រការ ៣:** ប្រកាសលេខ ២៣០ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ និងប្រកាសលេខ ១៩០ សហវ.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវសហការ និងអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០១៣

គាត ឈន់

<u>កន្លែងទទួល:</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ